Australian Early Development Census
An Australian Government Initiative

NSW GOVERNMENT

# ជំរឿនការអភិវឌ្ឍន៍កុមារតូចអូស្ត្រាលី (AEDC)

## ការប្រមូល ការការពារ និងការប្រើប្រាស់ទិន្នន័យ AEDC

### តើព័ត៌មានអ្វីខ្លះត្រូវបានប្រមូល?

ទិន្នន័យដែលប្រមូលជាផ្នែកនៃ AEDC នឹងរួមបញ្ចូលព័ត៌មានផ្ទាល់ខ្លួនអំពីកូនរបស់អ្នក រួមមានឈ្មោះ អាសយដ្ឋាន ប្រវត្តិវប្បធម៌ និងភាសា ហើយនិងព័ត៌មានអំពីសុខភាពរបស់ពួកគេ។ ព័ត៌មាននេះអាចត្រូវបានយកចេញពីកំណត់ត្រាសាលា ដើម្បីជួយគ្រូបំពេញ AEDC។

នៅពេលបំពេញ AEDC គ្រូអាចត្រូវបានគាំទ្រដោយអ្នកប្រឹក្សាផ្នែកវប្បធម៌ដែលជាបុគ្គលិក ឬអ្នកម៉ៅការនៃសាលារៀនរបស់យើង ហើយអាចជួយពួកគេឱ្យយល់ដឹងពីបរិបទវប្បធម៌របស់កុមារប្រជាជាតិដំបូង។

### តើទិន្នន័យ AEDC ត្រូវបានគ្រប់គ្រងដោយរបៀបណា?

AEDC ត្រូវបានគ្រប់គ្រងដោយអនុលោមតាមគោលការណ៍ឯកជនភាពអូស្ត្រាលី (Australian Privacy Principles (APPs))។ APPs គ្រប់គ្រងការប្រមូល ការប្រើប្រាស់ ការលាតត្រដាង និងការផ្ទុកព័ត៌មានផ្ទាល់ខ្លួនដោយទីភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលី និងអង្គការវិស័យឯកជនមួយចំនួន ហើយជាផ្នែកនៃ*ច្បាប់ឯកជនភាព ឆ្នាំ 1998 (Privacy Act 1998* (Cth)*)*។

ព័ត៌មានផ្ទាល់ខ្លួនអំពីកូនរបស់អ្នកនឹងត្រូវបានប្រើប្រាស់ដើម្បីភ្ជាប់ទិន្នន័យ AEDC ជាមួយនឹងព័ត៌មានពីអង្គការផ្សេងទៀត ដូចជាមន្ទីរសុខាភិបាលដែលនឹងរក្សាវាការសម្ងាត់។ លទ្ធផល AEDC របស់កូនអ្នក នឹងត្រូវបានរក្សាទុកដាច់ដោយឡែកពីព័ត៌មានដែលកំណត់អត្តសញ្ញាណរបស់ពួកគេ ហើយគ្មាននរណាម្នាក់នឹងអាចចូលប្រើប្រាស់ព័ត៌មានទាំងពីរនេះក្នុងពេលតែមួយបានទេ។

លទ្ធផល AEDC សម្រាប់កុមារម្នាក់ៗមិនត្រូវបានគេយកធ្វើរបាយការណ៍ទេ ហើយទិន្នន័យ AEDC ដែលបានបោះពុម្ពផ្សាយទាំងអស់គឺមិនបញ្ចេញឈ្មោះ មានន័យថាឈ្មោះ អាយុ អាសយដ្ឋាន និងព័ត៌មានដែលកំណត់អត្តសញ្ញាណផ្សេងទៀតត្រូវបានដកចេញ មុនពេលទិន្នន័យត្រូវបានបោះពុម្ពផ្សាយ។

អ្នកអាចមើលពីរបៀបដែលទិន្នន័យត្រូវបានប្រមូល និងលាតត្រដាង ដោយចូលទៅកាន់គេហទំព័រ www.aedc.gov.au/data។ ទិន្នន័យពីការប្រមូលឆ្នាំ 2024 នឹងត្រូវបានបង្ហាញតាមរបៀបស្រដៀងគ្នា។

### តើទិន្នន័យ AEDC ត្រូវបានចែករំលែកជាមួយអ្នកណា ហើយវាត្រូវបានចែករំលែកដោយរបៀបណាដែរ?

#### សាលារៀន

សាលារៀនដែលមានសិទ្ធិ ទទួលបានលទ្ធផលសង្ខេបនៃ AEDC នៅក្នុងទម្រង់នៃកម្រងព័ត៌មានសាលា។ កម្រងព័ត៌មានសាលាមិនរាយការណ៍ពីលទ្ធផល AEDC ណាមួយអំពីកុមារម្នាក់ៗទេ។

សាលារៀនអាចចែករំលែកកម្រងព័ត៌មានរបស់ពួកគេជាមួយស្ថាប័នផ្សេងទៀត ឬមនុស្សដែលមានទំនុកចិត្ត សម្រាប់គោលបំណងនានាដូចជាការគាំទ្រកុមារឱ្យកាន់តែប្រសើរឡើង ប៉ុន្តែមិនអាចធ្វើឱ្យកម្រងព័ត៌មាននោះជាសាធារណៈបានទេ។ ដើម្បីការពារឯកជនភាពរបស់កុមារបន្ថែមទៀត សាលារៀនដែលមានកុមារតិចជាងប្រាំមួយនាក់ដែលចូលរួមក្នុង AEDC នឹងមិនទទួលបានកម្រងព័ត៌មានសាលាទេ។

#### រដ្ឋាភិបាល និងស្ថាប័នកំពូលវិស័យសាលា

ក្រសួងរដ្ឋាភិបាលថ្នាក់រដ្ឋ និងដែនដី និងស្ថាប័នកំពូលរបស់សាលាកាតូលិក និងសាលាឯករាជ្យ នឹងទទួលបានព័ត៌មានអនាមិកសម្រាប់កុមារទាំងអស់នៅក្នុងវិស័យសាលារបស់ពួកគេ។

#### ការរួមបញ្ចូលអាជ្ញាធរ និងអង្គភាពតភ្ជាប់ទិន្នន័យនានា

ទីភ្នាក់ងារដែលបានជ្រើសរើសនឹងទទួលបានព័ត៌មានផ្ទាល់ខ្លួនអំពីកុមារដែលចូលរួមក្នុង AEDC ដើម្បីភ្ជាប់លទ្ធផល AEDC របស់ពួកគេជាមួយនឹងទិន្នន័យផ្សេងទៀត។ អាស្រ័យលើយន្តការដែលបានប្រើប្រាស់សម្រាប់ការភ្ជាប់ទិន្នន័យ ពួកគេក៏អាចទទួលបានលទ្ធផល AEDC អនាមិកផងដែរ។ ទីភ្នាក់ងារទាំងនេះរួមមានទីភ្នាក់ងារសហព័ន្ធ រដ្ឋាភិបាលថ្នាក់រដ្ឋ និងដែនដី សកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវដែលបានបង្ហាញថាមានប្រព័ន្ធសុវត្ថិភាពគ្រប់គ្រាន់ដើម្បីការពារឯកជនភាពរបស់កុមារ។

#### អ្នកស្រាវជ្រាវ

អ្នកស្រាវជ្រាវអាចស្នើសុំទិន្នន័យ AEDC អនាមិក និងទិន្នន័យ AEDC ដែលបានភ្ជាប់ទៅនឹងទិន្នន័យផ្សេងទៀតដើម្បីឆ្លើយសំណួរស្រាវជ្រាវនានា។ សម្រាប់ឧទាហរណ៍អំពីរបៀបដែលអ្នកស្រាវជ្រាវបានប្រើប្រាស់ទិន្នន័យ AEDC សូមចូលទៅកាន់គេហទំព័រ https://www.aedc.gov.au/snapshots

ទិន្នន័យ AEDC អនាមិកក៏ត្រូវបានចែករំលែកជាមួយវិទ្យាស្ថានស្រាវជ្រាវនានាដែលរួមចំណែកដល់កម្មវិធី AEDC ផងដែរ។ ក្នុងករណីខ្លះ ទិន្នន័យអនាមិកអាចត្រូវបានផ្តល់ជូនទៅវិទ្យាស្ថានស្រាវជ្រាវនៅបរទេស។

#### ទីភ្នាក់ងារគ្រប់គ្រងទិន្នន័យ AEDC

ព័ត៌មានផ្ទាល់ខ្លួន និងលទ្ធផល AEDC អនាមិកត្រូវបានកាន់កាប់ និងគ្រប់គ្រងក្នុងនាមក្រសួងអប់រំរបស់រដ្ឋាភិបាលអូស្ត្រាលី ដោយទីភ្នាក់ងារគ្រប់គ្រងទិន្នន័យដែលបានតែងតាំង។ ទីភ្នាក់ងារគ្រប់គ្រងទិន្នន័យ AEDC ត្រូវបានជ្រើសរើសយ៉ាងប្រុងប្រយ័ត្ន ដើម្បីធានាថាទិន្នន័យ AEDC ត្រូវបានគ្រប់គ្រងដោយអនុលោមតាមស្តង់ដារសុវត្ថិភាពខ្ពស់បំផុត។ ទីភ្នាក់ងារគ្រប់គ្រងទិន្នន័យ AEDC បច្ចុប្បន្នគឺមជ្ឈមណ្ឌលស្រាវជ្រាវសង្គម។